World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨២

របាយការណ៍គិតត្រឹមថ្ងៃទី ៧ ខែមីនា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី២១ កុម្ភៈ ដល់ថ្ងៃ ៦ មីនា ឆ្នាំ២០២២)

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី សរុបចំនួន ៥.៧៣១ និងករណីស្លាប់ថ្មីដោយសារជំងឺកូវីដ-១៩ចំនួន២២ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ៥.៧៣១ ករណីនោះ ៩៤ភាគរយជាករណីឆ្លងក្នុងសហគមន៍ ហើយ៦ភាគរយជាករណីនាំចូលពីក្រៅប្រទេស។ កម្ពុជាកំពុងមានករណីឆ្លងជំងឺកូវីដ-១៩កើនឡើងជាគំហុក និងមានការឆ្លងក្នុងសហគមន៍ទូលំទូលាយនៅរាជធានីភ្នំពេញ។
- ករណីសរុបទាំងអស់ចំនួន ១៣២.៧០៨ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៤២ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ១២៦.៩២១ ករណីបានជាសះស្បើយ។
- គិតត្រឹមថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៥៦២.៧៩៧ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)។ គិតចាប់តាំងពីខែមករា ឆ្នាំ ២០២០មក បុគ្គលសរុបចំនួន ១.៨៣១.៦៥៦ នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥.២ ភាគរយ។
- កម្ពុជាកំពុងមានករណីឆ្លងកើនឡើងជាគំហុកដោយសារចរចររបស់មេរោគកូវីដ-១៩បំប្លែងថ្មីអូមីក្រុងនៅក្នុងសហគមន៍ដោយមានការឆ្លងជាចង្កោមនៅតាមទីកន្លែងមួយចំនួនដូចជាតាមសាលារៀន កន្លែងធ្វើការ និងកន្លែងកម្សាន្ត។ ការធ្លាក់ចុះនូវករណីឆ្លងមួយចំនួនកន្លងមក ប្រហែលដោយសារតែចំនួនធ្វើតេសរកមេរោគកូវីដ-១៩តិចជាងមុន។ ចំនួនអ្នកជំងឺស្នាក់នៅមន្ទីរពេទ្យកើនឡើង បើទោះបីជាសមត្ថភាពថែទាំសុខភាពស្ថិតនៅក្នុងស្ថានភាពល្អប្រសើរនៅឡើយ។ ការកែតម្រូវវិធានការសុខភាពសាធារណៈ និងសង្គមដើម្បីទប់ស្កាត់កុំឱ្យមានការចម្លងទ្រង់ទ្រាយធំ ការពង្រឹងការផ្តល់សេវាសុខភាព និងពន្លឿនការចាក់វ៉ាក់សាំងនៅតែជាផ្នែកអាទិភាពដើម្បីគ្រប់គ្រងបញ្ហាកូវីដ-១៩ និងបញ្ហាផ្សេងៗនាពេលអនាគតប្រកបដោយនិរន្តរភាព។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- **ការតាមដានជំងឺ:**
  - ❖ អង្គការសុខភាពពិភពលោក បានផ្តល់ការគាំទ្រដល់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលដើម្បីពិនិត្យកម្មវិធីតាមដានជំងឺដែលជាផ្នែកមួយនៃផែនការការងារថ្នាក់ជាតិឡើងវិញ និងកំណត់អាទិភាពសម្រាប់ឆ្នាំ២០២២ រួមទាំងការពិនិត្យនូវប្រព័ន្ធតាមដានជំងឺផ្តាសាយឡើងវិញ។
  - ❖ អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលនៅក្នុងការវាយតម្លៃការប្រើតេស្តរហ័ស ការតាមដានជំងឺ និងការកែតម្រូវវិធានការសុខភាពសាធារណៈ និងសង្គមឡើងវិញ។
  - ❖ អង្គការសុខភាពពិភពលោក កំពុងផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់ការបង្កើតប្រព័ន្ធតាមដានលំដាប់ហ្សែនវិភាគរកប្រភេទនៃមេរោគបំប្លែងថ្មី រួមទាំងពិនិត្យឡើងវិញនូវសមត្ថភាពថែទាំសុខភាព និងប្រព័ន្ធសុខាភិបាលនាពេលបច្ចុប្បន្ន។
  - ❖ គោលការណែនាំរបស់ក្រសួងសុខាភិបាលស្តីពីការស្វែងរកអ្នកប៉ះពាល់ និងការធ្វើចត្តាឡីស័ក ត្រូវបានពិនិត្យឡើងវិញ ហើយកំណែប្រែថ្មីមួយត្រូវបានធ្វើបង្កើយ។

## វិធានការសុខភាពសាធារណៈ និងសង្គម

- កាលពីថ្ងៃទី ២១ ខែកុម្ភៈ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត បានចេញសេចក្តីជូនដំណឹងស្តីពីការដាក់អនុវត្តការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុកតាមគន្លងប្រតីភាពថ្មីសម្រាប់អាជីវកម្មហាង និងផ្សារទាំងអស់តាមរយៈគេហទំព័រ www.camccms.org ខណៈដែលក្រសួងទេសចរណ៍ បានចេញសេចក្តីណែនាំឱ្យមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មទេសចរណ៍។ ពង្រឹងការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍។
- កាលពីថ្ងៃទី ២៨ ខែកុម្ភៈ រដ្ឋបាលខេត្តសៀមរាប បានចេញសេចក្តីណែនាំឱ្យស្នងការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងសៀមរាប រដ្ឋបាលក្រុង-ស្រុក មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត មន្ទីរទេសចរណ៍ មន្ទីរ-អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលឃុំ-សង្កាត់ជួយបន្តជំរុញផ្សព្វផ្សាយគ្រប់រូបឱ្យមានការចូលរួមអនុវត្តនូវវិធានការសុខាភិបាល និងវិធានការផ្សេងៗទៀត ឱ្យភោជនីយដ្ឋាន-អាហារដ្ឋានបង្កើនការយកចិត្តទុកដាក់ក្នុងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋទូទៅ និងអ្នករៀបចំកម្មវិធីជួបជុំឱ្យកាត់បន្ថយនូវការជួបជុំគ្នាច្រើន និងប្រើប្រាស់ឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- អង្គការសុខភាពពិភពលោក ផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រសួងសុខាភិបាលដើម្បីជម្រុញការអនុវត្តនូវវិធានការសុខភាពសាធារណៈ និងសង្គមដូចជាការពាក់ម៉ាស់នៅពេលចេញក្រៅ ការលាងសម្អាតដៃញឹកញាប់ជាមួយនឹងសាប៊ូ ការជៀសវាងកន្លែងជួបជុំ និងពិធីជួបជុំមនុស្សកុះករ និងទៅចាក់វ៉ាក់សាំងនៅពេលដល់វេនអ្នក ជាពិសេសផ្តោតទៅលើស្ត្រីមានផ្ទៃពោះនៅលើបណ្តាញផ្សព្វផ្សាយទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម។ ស្ប៉ត់វីដេអូ និងវិទ្យុ ត្រូវបានរៀបចំផលិតជាភាសាខ្មែរ។
- អង្គការសុខភាពពិភពលោកបានធ្វើការជាមួយនឹងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពក្នុងការធ្វើបង្កើយនូវផែនការពង្រឹងការចូលរួមរបស់សហគមន៍សម្រាប់ខេត្តអាទិភាពចំនួន៩។ ការគាំទ្ររួមមានជំនួយផ្នែកបច្ចេកទេសដើម្បីរៀបចំកិច្ចប្រជុំធ្វើផែនការតាមអនឡាញដោយមានការចូលរួមពីមន្ទីរសុខាភិបាលខេត្ត និងពិនិត្យឡើងវិញនូវសកម្មភាពចូលរួមរបស់សហគមន៍។ កិច្ចប្រជុំនោះផ្តោតលើការកសាងសមត្ថភាព និងកិច្ចសន្ទនាសហគមន៍ដើម្បីកំណត់ពីបញ្ហា និងដំណោះស្រាយពីមូលដ្ឋាន ក៏ដូចជាគាំទ្រដល់ការងារតាមដានជំងឺក្នុងសហគមន៍ ការត្រួតពិនិត្យ និងរាយការណ៍ទៅកាន់មណ្ឌលសុខភាព។
- អង្គការសុខភាពពិភពលោក កំពុងសហការជាមួយនឹងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើម្បីធ្វើបង្កើយផែនការសម្រាប់យុទ្ធនាការជាតិផ្សព្វផ្សាយការយល់ដឹងដែលរំពឹងថានឹងចាប់ផ្តើមនាពាក់កណ្តាលខែមីនាឆ្នាំ២០២២នេះ ដើម្បីលើកកំពស់ និងជម្រុញឱ្យមានការចូលរួមពីបុគ្គល និងគ្រួសារក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រចាំថ្ងៃបានត្រឹមត្រូវដើម្បីទប់ស្កាត់កុំឱ្យការចម្លងទ្រង់ទ្រាយធំនៅកម្ពុជា។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- ទូបង្កកត្រជាក់ខ្លាំង (ultra-low temperature, ULT: -90°C) ចំនួន៣៣គ្រឿងសម្រាប់រក្សាទុកវ៉ាក់សាំងPfizer និងទូបង្កកត្រជាក់ (-20°C) ចំនួន១០០គ្រឿងបានចែកចាយទៅតាមបណ្តាខេត្តក៏ដូចជាការិយាល័យស្រុកប្រតិបត្តិផងដែរ។
- វ៉ាក់សាំងប្រភេទ Pfizer ត្រូវបានចែកចាយទៅតាមបណ្តាខេត្តចំនួន១០ ដូចជាខេត្តស្វាយរៀង ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រះសីហនុ និងខេត្តកណ្តាលដែលបានតំឡើងទូបង្កកត្រជាក់ខ្លាំង (-90°C) និងទូបង្កកត្រជាក់ (-20°C) នៅការិយាល័យស្រុកប្រតិបត្តិរួចហើយ។
- ការចាក់វ៉ាក់សាំងដូសទី៤ប្រភេទ Pfizer នៅខេត្តទាំង១០ខាងលើ នឹងចាប់ផ្តើមនៅសប្តាហ៍ក្រោយ។
- វ៉ាក់សាំងប្រភេទ Pfizer ដែលជាបំណែងចែកពីអាស៊ានចំនួន ១៣៩.000ដូស នឹងមកដល់កម្ពុជានៅសប្តាហ៍ទី២នៃខែមីនានេះ។ គិតត្រឹមថ្ងៃទី ៦ ខែមីនា ឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលកម្ពុជាទទួលបានវ៉ាក់សាំងកូវីដ-១៩ចំនួន ៤៣.៧៩២.៥៣០ ដូស ហើយវ៉ាក់សាំងកូវីដ-១៩ ចំនួន ៤.១៨០.០៩៦ ដូសនៅសល់ក្នុងស្តុក។
- ការគាំទ្ររបស់អង្គការសុខភាពពិភពលោកដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការៈ
  - បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការចាក់វ៉ាកសាំង Pfizer និងការគ្រប់គ្រងវ៉ាក់សាំងដល់មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពកាលពីថ្ងៃទី ៥ ខែមីនា ឆ្នាំ២០២២។
  - បានចុះត្រួតពិនិត្យនៅមណ្ឌលចាក់វ៉ាក់សាំងនៅរាជធានីភ្នំពេញ។
  - បានបង្កើយផែនការសកម្មភាពសម្រាប់សកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ចំនួន។
  - ការពិនិត្យឡើងវិញនូវផែនការជាតិដាក់ពង្រាយ និងចាក់ថ្នាំបង្ការសម្រាប់វ៉ាក់សាំងកូវីដ-១៩។
  - ការវិភាគ និងរបាយការណ៍អំពីការចាក់វ៉ាក់សាំង និងទិន្នន័យអំពីហេតុការណ៍កើតឡើងក្រោយពេលចាក់វ៉ាក់សាំង រួមទាំងការចែករំលែកព័ត៌មានដល់ភាគីពាក់ព័ន្ធ។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- កិច្ចពិភាក្សាករណីគ្លីនិកតាមប្រព័ន្ធអនឡាញមួយត្រូវបានរៀបកាលពីថ្ងៃទី ២២ ខែកុម្ភៈ ថ្ងៃទី ១ និងទី២ ខែមីនា ដោយមានការធ្វើបទបង្ហាញករណីគ្លីនិកពីខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។
- ការបង្ហាត់បង្ហាញផ្ទាល់ពីរបៀបព្យាបាលដោយប្រើអុកស៊ីសែន ត្រូវបានរៀបចំកាលពីសប្តាហ៍មុននៅមន្ទីរពេទ្យបង្អែកស្រុកចំនួន៤ នៃខេត្តកំពត។ យ៉ាងហោចណាស់ក៏បុគ្គលិកចំនួន១០នាក់មកពីមន្ទីរពេទ្យនីមួយៗ បានចូលរួមក្នុងការបង្ហាត់បង្ហាញដោយផ្ទាល់នេះ។
- ឯកសារណែនាំរស់របស់អង្គការសុខភាពពិភពលោកស្តីអំពីការព្យាបាល និងជំងឺកូវីដ-១៩ ត្រូវបានធ្វើបច្ចុប្បន្នភាពដោយដាក់បញ្ចូលនូវអានុសាសន៍ដោយមានលក្ខខណ្ឌអំពីការប្រើប្រាស់ថ្នាំ Molnupiravir សម្រាប់អ្នកជំងឺដែលមិនធ្ងន់ធ្ងរដែលមានហានិភ័យខ្ពស់បំផុត



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ក្នុងការចូលមន្ទីរពេទ្យដូចជាអ្នកដែលមិនបានចាក់វ៉ាក់សាំង មនុស្សចាស់ អ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយ និងអ្នកមានជំងឺប្រចាំកាយ។

- អង្គការសុខភាពពិភពលោក កំពុងសហការជាមួយនឹងក្រសួងសុខាភិបាល ដើម្បីពង្រឹងការព្យាបាល ថែទាំអ្នកជំងឺកូវីដ-១៩នៅតាមផ្ទះ និងតាមដានជំងឺនៅតាមមន្ទីរពេទ្យដើម្បីបញ្ចៀសបញ្ហាលើសពីសមត្ថភាពថែទាំសុខភាពរួមទាំងការពិនិត្យឯកសារប្រាស្រ័យទាក់ទង និងគោលការណែនាំឡើងវិញ។ ការស្ទង់មតិមួយស្តីពីការថែទាំ និងព្យាបាលនៅតាមផ្ទះ នឹងត្រូវរៀបចំធ្វើតាមពីថ្ងៃទី ១៤ ខែមីនានៅក្នុងខេត្តចំនួន៥។

## អេពីដេមីសាស្ត្រ

### ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១-២០២២ *




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## តារាងទី១. តារាងសង្ខេបអំពីស្ថានភាពកូវីដ-១៩

| | | | | |
|---|---|---|---|---|
| **បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩** | ចំនួនតេស្ត | ករណីឆ្លង | ករណីស្លាប់ | |
| | 10,617<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | 5,731<br>ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | 22<br>ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | 333<br>ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | 2,562,797<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 132,708<br>ករណីសរុប | 3,042<br>ករណីស្លាប់សរុប | |
| **ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩** | 79<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែអ្នកជំងឺធ្ងន់ដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល | |

## តារាងទី២. ការវាយតម្លៃ[1]អំពីដំណាក់កាលចម្លងតាមខេត្តនីមួយៗ

| ដំណាក់កាលចម្លង | ខេត្ត |
|---|---|
| ដំណាក់កាលចម្លងទី៣: ការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ | រាជធានីភ្នំពេញ |
| ដំណាក់កាលចម្លងទី២: ការឆ្លងក្នុងសហគមន៍តាមតំបន់ | ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តកោះកុង ខេត្តកែប ខេត្តក្រចេះ និងខេត្តប៉ៃលិន |
| ដំណាក់កាលចម្លងទី១: ករណីនាំចូល | ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី |

[1] តំណាក់កាលចម្លងសម្រាប់ការចាត់ថ្នាក់កម្រិតថ្នាក់ក្រោមជាតិដោយអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៣. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញវ័យ និងកុមារ)**

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | យុវវ័យ និងកុមារ | | | |
|---|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៣-៤ ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ | អាយុចាប់១២ ឆ្នាំដល់ក្រោម ១៨ឆ្នាំ |
| | **(N=43,646)** | **(N=1,378,688)** | **(N=10,000,000)** | **(N=610,730)** | | **(N=1,897,382)** | **(N=1,827,348)** |
| **ចាប់ផ្តើម (2021)** | **10 កុម្ភៈ 2021** | **10 កុម្ភៈ 2021** | **10 កុម្ភៈ:2021** | **22 កុម្ភៈ 2022** | **1 វិច្ឆិកា 2021** | **17 កញ្ញា 2021** | **1 សីហា 2021** |
| **ដូសទី១** | 43,646 (100%) | 1,406,508 (102.0%) | 10,248,592 (102.5%) | 222,404 (36.4%) | 361,184 (118.7%) | 2,034,061 (107.2%) | 1,826,933 (100.0%) |
| **ដូសទី២** | 43,646 (100%) | 1,389,421 (100.8%) | 9,897,272 (99.0%) | N/A | 263,320 (86.5%) | 1,947,992 (102.7%) | 1,757,849 (96.2%) |
| **ដូសទី៣** | 5,702,630 (57.0%) | | | N/A | | 611,461 (32.2%) | 1,114,053 (61.0%) |
| **ដូសទី៤** | 1,027,580 (10.3%) | | | | | N/A | N/A |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៤. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩**

| ប្រភេទវ៉ាក់សាំងកូវីដ-១៩ | Sinovac | Sinopharm | AstraZeneca (Covishield) | Janssen (Ad26.COV2-S) | AstraZeneca (Vaxzevria) | Moderna (Spikevax) | Pfizer BioNTech (Comirnary) | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 100 | 79 | 29 | 4 | 1 | 2 | 0 | **215** |
| ចំនួនដូសសរុបបានចាក់ | 23,383,154 | 7,438,328 | 323,344 | 1,053,151 | 2,616,220 | 334,768 | 813,215 | **35,962,180** |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.43 | 1.06 | 8.97 | 0.38 | 0.08 | 0.60 | 0 | **0.60** |

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។